# ច្បាប់

# ស្តីពី

# ការផ្តន្ទាទោសអំពើភេរវកម្ម

Downloaded from http://www.khmerlaws.com

# រដ្ឋកម្ពុជា

រដ្ឋសភា ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

# ច្បាប់
# ស្តីពី
# ការផ្តន្ទាទោសអំពើភេរវកម្ម

**មាត្រា ១.-**

អំពើភេរវកម្ម ជាអំពើហឹង្សាទាំងឡាយ ដែលប្រព្រឹត្តដោយជនមួយនាក់ ឬជនមួយក្រុម ឬច្រើនក្រុម បង្កើតភាពភិតភ័យតក់ស្លុតក្នុងចំណោមប្រជាជន ក្នុងគោលដៅធ្វើឱ្យជ្រួលច្របល់យ៉ាងខ្លាំងដល់សណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ និងអោយ ប៉ះពាល់ដល់ស្ថេរភាពនយោបាយ ។

**មាត្រា ២.-**

ជនណាចាប់ពង្រត់មនុស្ស ឬបង្ខាំងមនុស្សដោយខុសច្បាប់ ក្នុងគោលដៅធ្វើវិច្ឆេទកម្ម ទារយកប្រាក់ សងសឹក ធ្វើជាចំណាប់ខ្មាំង យកទៅលក់ និងជនណាដែលប្រព្រឹត្តអំពើភេរវកម្មផ្សេងៗ ទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១០ឆ្នាំ ដល់ ២០ឆ្នាំ ។

ប្រសិនបើការចាប់ពង្រត់ បង្ខាំងមនុស្សដោយខុសច្បាប់ ឬអំពើភេរវកម្មនោះធ្វើទៅលើអនីតជន ឬបណ្តាលអោយជនរងគ្រោះស្លាប់ ជនប្រព្រឹត្តល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ដោយឥតគិតពីស្ថានត្រាប្រណីទោស ។

**មាត្រា ៣.-**

ជនណាដែលប៉ុនប៉ងសម្លាប់មនុស្ស ឬសម្លាប់មនុស្សដោយចេតនា គិតទុកជាមុនក្នុងគោលដៅធ្វើភេរវកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ដោយឥតគិតពីស្ថានភាពត្រាប្រណីទោស ។

**មាត្រា ៤.-**

ច្បាប់នេះត្រូវបានប្រកាសជាប្រញាប់ ។

ច្បាប់នេះត្រូវបានរដ្ឋសភានៃរដ្ឋកម្ពុជា អនុម័តនៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩២ នាសម័យប្រជុំលើកទី ២២ នីតិកាលទី ១ ។

ភ្នំពេញ.ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩២

ជ.រដ្ឋសភា

ប្រធាន

ហត្ថលេខា និងត្រា ជាស៊ីម

បានចម្លងតាមច្បាប់ដើម

អគ្គលេខាធិការក្រុមប្រឹក្សារដ្ឋ

ហត្ថលេខា និងត្រា

ចាន់ វ៉ែន

ចេញក្រឹត្យ ១០ ចុះ ០៧ /០២ /១៩៩២

Downloaded from http://www.khmerlaws.com